「ប្រាក់កក់」 នឹង 「ការធ្វើអោយដូចភាពដើម」

ចាប់តាំងពីជួលបន្ទប់រហូតដល់ពេលចេញវិញត្រូវមានលក្ខខណ្ឌនឹងការបំពេញបែបបទផ្សេងៗ។

សៀវភៅណែនាំនេះលើកឡើងជាពិសេសស្តីពី 「ប្រាក់កក់」 នឹង 「ការធ្វើអោយមានភាពដូចដើម」

- ការទូទាត់ប្រាក់កក់នឹងការធ្វើអោយមានភាពដូចដើម
- ដំណើរការរបស់ប្រាក់កក់នឹងការធ្វើអោយមានភាពដូចដើម
- ការពន្យល់អំពីវិធីប្រើប្រាស់បន្ទប់ ពេលចូលមករស់នៅនឹងពេលចេញ

## ស្តីពីអង្គការNPO មជ្ឈមណ្ឌលទ្រទ្រង់លំនៅដ្ឋានសម្រាប់ជនបរទេសខេត្តកាណាហ្គាវ៉ា

មជ្ឈមណ្ឌលទ្រទ្រង់លំនៅដ្ឋានសម្រាប់ជនបរទេសខេត្តកាណាហ្គាវ៉ាគឺជាមជ្ឈមណ្ឌលសម្រាប់ជួយក្នុងការស្វែងរកបន្ទប់ជួលដល់ជនបរទេសដែលមានភាសាកំណើតក្រៅពីភាសាជប៉ុន។




អង្គការNPOមជ្ឈមណ្ឌលទ្រទ្រង់
លំនៅដ្ឋានសម្រាប់ជនបរទេសខេត្តកាណាហ្គាវ៉ា
យ៉ូកូហាម៉ាសីុណាកាខឺចុខិវ៉ាចូ1-7
យ៉ូកូហាម៉ាYMCAជាន់ទី2
TEL 045-228-1752
FAX 045-228-1768
e-mail : sumai.sc@sumasen.com
http://www.sumasen.com/

JR・ដើរ5នាទីពីចំណតខ្សែរថភ្លើងក្រោមដីស្ថានីយខាន់ណៃ, ដើរ5នាទីពីចំណតខ្សែរថភ្លើងមិណាតុមិរៃ ស្ថានីយនីហុនអូរដុអូរិ

ធ្វើឡើងនៅឆ្នាំ2020ខែកុម្ភៈ

អង្គការNPOមជ្ឈមណ្ឌលទ្រទ្រង់លំនៅដ្ឋានសម្រាប់ជនបរទេសខេត្តកាណាហ្គាវ៉ាបានទទួលការប្រគល់កិច្ចពីខេត្តកាណាហ្គាវ៉ាហើយបានបង្កើតសៀវភៅណែនាំនេះ។

ការិយាល័យខេត្តកាណាហ្គាវ៉ាផ្នែករប្បធម៌ទេសចរណ៍អន្តរជាតិ(យ៉ូកូហាម៉ាសុ ី ណាកាខឺ នីហុនអូរដុអូរិ1)

TEL 045-210-1111　លេខបន្តរផ្ទាប់ទូរសព្ទ3748　　FAX 045-212-2753

1 សូមយល់ដឹងអំពីបែបបទរបស់ 「ការជួលបន្ទប់នឹងការរើចេញ」

A ចុះកិច្ចកុងត្រាដើម្បីជួលបន្ទប់

B ដម្កល់ប្រាក់កក់នៅក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ

លោកអ្នកត្រូវធ្វើកិច្ចការទាំងនេះជាមួយក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ

C ពិនិត្យមើលបន្ទប់មុននឹងចូលទៅរស់នៅ

(ត្រូវពិនិត្យមើលបន្ទប់ជាមួយក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះថាតើមានកន្លែងណាដែលប្រឡាក់ឬបែកបាក់ខូចខាតឬទេ)

កិច្ចការដែលលោកអ្នកត្រូវធ្វើ

D រស់នៅក្នុងបន្ទប់ដែលបានជួល

E ផ្ដល់ដំណឹងជាមុននៅពេលដែលរើចេញ

(ប្រាប់ទៅក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះថានឹងត្រូវរើចេញ)

F រើចេញពីបន្ទប់ (យកអីវ៉ាន់ចេញពីបន្ទប់)

G អ្នកត្រូវធ្វើអោយបន្ទប់មានភាពដូចដើម(ដូចពេលដែលមុននឹងចូលមករស់នៅ)

កិច្ចការដែលលោកអ្នកត្រូវធ្វើជាមួយក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ

H ពិនិត្យមើលបន្ទប់នៅពេលរើចេញ

ត្រូវពិនិត្យមើលបន្ទប់ជាមួយក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះថាតើមានកន្លែងណាដែលប្រឡាក់ឬបែកបាក់ខូចខាតឬទេ

I ក្រុមហ៊ុនជំនាញនឹងជួសជុលធ្វើអោយមានភាពដូចដើម(ដូចពេលដែលមុននឹងចូលមករស់នៅ)

J ក្រុមហ៊ុនជំនាញនឹងទូទាត់ប្រាក់ក្នុងការជួសជុល

K ទូទាត់ជាមួយប្រាក់កក់(ក្រោយពីជួសជុលអោយមានភាពដូចដើមបានរួចរាល់។ក្នុងករណីនៅសេសសល់ប្រាក់នឹងត្រូវបានសងជូន

## 2 សូមចងចាំពាក្យសំខាន់ៗ

### (1) ប្រាក់កក់ Shikikin

នៅពេលចុះកិច្ចកុងត្រាត្រូវប្រគល់ប្រាក់កក់ទៅអោយក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ។ដោយទូទាត់ថ្លៃផ្ទះចំនួនប៉ុន្មានខែទុកជាមុន(ចំនួនខែគឺខុសគ្នាទៅតាមកិច្ចកុងត្រា)

ប្រាក់កក់នឹងត្រូវបានយកទៅទូទាត់នៅពេលដែលរើចេញ

ក្នុងករណីមានបែកបាក់ខូចខាតហើយចំបាច់ត្រូវជួសជុល,សម្អាតកន្លែងណាដែលប្រឡាក់,យកទៅបង់ថ្លៃផ្ទះដែលលោកអ្នកមិនបានបង់ជាដើម។

### (2) ការទូទាត់ប្រាក់កក់ Shikikin no seisan

នៅពេលដែលរើចេញ

ថ្លៃជួសជុលបន្ទប់នឹងថ្លៃសម្អាតឬមានការជំពាក់ថ្លៃជួលផ្ទះត្រូវបានទូទាត់ជាមួយប្រាក់កក់។ក្នុងករណីនៅសល់(ប្រាក់កក់)នឹងត្រូវបានសងជូនតែបើខ្វះលោកអ្នកត្រូវបង់ប្រាក់បន្ថែម។

### (3) ការធ្វើអោយមានភាពដូចដើម Genjou kaifuku

「ធ្វើអោយមានភាពដូចដើម」បានន័យថាដូចពេលដែលមុននឹងចូលមករស់នៅ។សម្អាតបន្ទប់បើមានប្រឡាក់

ជួសជុលកន្លែងណាដែលរហែកខូចខាត រៀបចំអីវ៉ាន់។បើលោកអ្នកធ្វើអោយបានដូចភាពដើមប្រាក់កក់ក៏ត្រូវបានសងមកវិញច្រើនដែរ។

### (4) ការពិនិត្យអាគារ Bukken kakunin

នៅពេលជួលបន្ទប់ត្រូវពិនិត្យជាមុនថាបន្ទប់(អាគារ)នោះមានប្រឡាក់រហែកឬក៏អត់។នៅពេលរើអីវ៉ាន់ចេញអស់ក៏ត្រូវពិនិត្យមើលដូចគ្នាដែរ។

យកល្អត្រូវពិនិត្យមើលជាមួយគ្នានឹងក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ។

### (5) ការអោយតំណឹងមុនពេលដែលរើចេញ Taikyo yokoku

សូមប្រាប់ទ្រៅកុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះជាមុននៅពេលចាកចេញ(រើចេញ)

នៅក្នុងកិច្ចកុងត្រាជួលផ្ទះមានកំណត់អោយប្រាប់រយះពេលប៉ុន្មានខែជាមុន។

នៅពេលដែលប្រាប់ទៅក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះនូវថ្ងៃរើចេញសូមកុំភ្លេចណាត់ថ្ងៃពិនិត្យមើលបន្ទប់ថាមានខូចខាតអ្វីខ្លះ។

## 3 សូមចងចាំចំណុចសំខាន់ៗ

(អ្នកដែលជាម្ចាស់ផ្ទះនៅក្នុងសៀវភៅនេះបានប្រើពាក្យថាក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ

អ្នកជួលផ្ទះ(អ្នកបង់ថ្លៃផ្ទះសម្រាប់លំនៅដ្ឋាន)នៅក្នុងសៀវភៅនេះបានប្រើពាក្យថាលោកអ្នក)

### A ចុះកិច្ចកុងត្រាដើម្បីជួលបន្ទប់

○ ក្នុងកិច្ចកុងត្រាមានចុះលក្ខខណ្ឌក្នុងការជួលបន្ទប់។

○ មានលក្ខខណ្ឌសំខាន់ៗជាច្រើន។ត្រូវអានដើម្បីអោយបានយល់ច្បាស់។

### B បង់ប្រាក់កក់ទៅក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ

### C ពិនិត្យមើលបន្ទប់មុននឹងចូលទៅរស់នៅ

(ត្រូវពិនិត្យមើលជាមួយគ្នានឹងក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះថាតើមានប្រឡាក់ឬរហែកឬក៏អត់។)

○ រវាង「លោកអ្នក」នឹង「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」ត្រូវពិនិត្យថាតើមានកន្លែងណាប្រឡាក់ឬរហែកឬក៏អត់។

○ ដើម្បីបង្ការកុំអោយមានបញ្ហាទៅថ្ងៃក្រោយ។បើអាចសូមថតរូបដែលមានចុះថ្ងៃខែហើយរក្សាទុក។

### D ការរស់នៅក្នុងបន្ទប់ដែលបានជួល

○ បើសិនជា「លោកអ្នក」ប្រើប្រាស់បន្ទប់តាមធម្មតា (ដូចជារស់នៅជាយូរឆ្នាំតាមធម្មតាហើយត្រូវប្រឡាក់ឬរហែក)「ម្ចាស់ផ្ទះ」នឹងចេញថ្លៃជួសជុលដើម្បីអោយដូចភាពដើមវិញ។

○ តែបើ「លោកអ្នក」ប្រើប្រាស់បន្ទប់មិនធម្មតាដោយមិនថែទាំលោកអ្នកត្រូវបង់លុយថ្លៃជួសជុលដោយផ្ទាល់ខ្លួន។

○ បើក្នុងកិច្ចកុងត្រាមានចុះលក្ខខណ្ឌពិសេសណាមួយគឺបុគ្គលដែលមាននៅក្នុងលក្ខខណ្ឌនោះត្រូវបង់ថ្លៃខូចខាត។សូមអានកិច្ចកុងត្រាអោយបានច្បាស់។

○ ប្រទេសជប៉ុនពោរពេញទៅដោយសំណើម។សូមប្រុងប្រយត្ន័ធាតុទឹកនឹងកុំអោយមានដុះផ្សិត។

○ នៅប្រទេសជប៉ុនបើលោកអ្នកប្រើប្រាស់បន្ទប់មានលើកឡើងដូចជាឧទាហរណ៍នៅខាងក្រោម「លោកអ្នក」ត្រូវបង់ថ្លៃខូចខាត។

＜កំរាល （កន្ទេល • ក្តារកំរាល • កំរាលព្រុំជាដើម） ＞

- បើមានកំពប់ម្ហូបចំណីឬកេសជ្ជះនៅលើកំរាលព្រុំធ្វើអោយជាប់ដាមឬដុះផ្សិត （សូមឧស្សាហ៍សម្អាត）
- ច្រេះដែលមាននៅខាងក្រោមទូទឹកកក （សូមឧស្សាហ៍សម្អាត）
- ស្នាមរហែកនៅពេលដែររើផ្ទះមកនៅ (សូមប្រយត្ន័នៅពេលដែលលើកអីវ៉ាន់)
- កំរាលដែលប្រែពណ៌ឬរលួយដោយសារទឹកឬភ្លៀង （សូមប្រញាប់ជូតទឹកចេញ）

＜ជញ្ជាំង、 ក្រដាសបិទជញ្ជាំង、 ដំបូលជាដើម＞

- ការប្រឡាក់ខ្លាញ់ឬស្នាមផ្សែងនៅជញ្ជាំងឬដំបូលចង្រ្កាន
  (បើបានប្រើប្រាស់ខ្លាញ់ក្នុងការចម្អិនហើយត្រូវសម្អាតអោយបានស្អាត។)
- ក្នុងករណីមានជាប់ស្នាមផ្សែងឬក្លិនបារីនៅនឹងជញ្ជាំង
- ក្នុងករណីដែល「លោកអ្នក」ដំដែកគោលឬចោះរន្ធខ្មៅ （សូមកុំចោះរន្ធនៅនឹងជញ្ជាំង）
- ក្នុងករណីដែល「លោកអ្នក」បានចោះរន្ធដំបូលដើម្បីតអំពូលភ្លើង
- ក្នុងករណីដែល 「លោកអ្នក」 បានគូសវាសនៅលើទ្វាឬជញ្ជាំង
- ក្នុងករណីដែល 「លោកអ្នក」

  មិនបានជូតដំណក់ទឹកនៅនឹងជញ្ជាំងឬក្រោមបង្អួច។បើសិនជាមានជាតិសំណើមនៅនឹងបង្អួចឬជញ្ជាំងសូមប្រាប់ទៅក្រុមហ៊ុនអចលនទ្រព្យឬក៏ម្ចាស់ផ្ទះ

  ពេលដែលបានប្រើម៉ាសុ ីនកំដៅឬចូលអាងត្រាំទឹកសូមបើកបង្អួចដើម្បីផ្លាស់ប្តូរខ្យល់

  បើមិនផ្លាស់ប្តូរខ្យល់ទេនឹងអាចធ្វើអោយមានជាប់ដំណក់ទឹក （សូមជូតដំណក់ទឹក）
- ពេលដែលលោកអ្នកមិនបានជូតទឹកដែលហូរចេញពីម៉ាសុ ីនត្រជាក់នៅក្នុងបន្ទប់ធ្វើអោយពុកជញ្ជាំងឬមានស្នាមប្រឡាក់ឬដុះផ្សិត

  (បើសិនជាមានទឹកដែលហូរចេញពីម៉ាសុ ីនត្រជាក់នៅក្នុងបន្ទប់សូមប្រាប់ទៅក្រុមហ៊ុនអចលនទ្រព្យឬក៏ម្ចាស់ផ្ទះ

  ហើយសូមជូតទឹក）
- បើសិនជាសត្វដែលលោកអ្នកចិញ្ចឹមបានធ្វើអោយរហែកឬជាប់ក្លិននៅជញ្ជាំង

  （សូមសួរបញ្ជាក់ទៅ「ក្រុមហ៊ុនអចលនទ្រព្យឬក៏ម្ចាស់ផ្ទះ」

  ថាតើអាចចិញ្ចឹមសត្វបានដែរឬទេ។ក្នុងកិច្ចកុងត្រាមានចុះអំពីលក្ខខណ្ឌនៃការចិញ្ចឹមសត្វ។）

＜សសរ,ទ្វា,ទ្វាបែបជប៉ុនជាដើម＞

・ នៅពេលដែល「លោកអ្នក」មានការដំដែកគោលឬដំខ្មៅនៅលើសសរ（សូមកុំចោះរន្ធនៅលើសសរ）

・ កន្លែងដែល「លោកអ្នក」បានគូសវាសឬធ្វើអោយរហែក

・ បើសិនជាសត្វដែលអ្នកចិញ្ចឹមបានធ្វើអោយរហែកឬជាប់ក្លិននៅលើសសរ

＜សម្ភារះ,សោ,សួនជាដើម＞

・ បើមានខ្លាញ់ឬផ្សែងជាប់នៅកង្ហារបូរខ្យល់ឬចង្ក្រានហ្គាស់（សូមសម្អាតអោយបានស្អាត）

・ ប្រឡាក់ដុះផ្សិតឬជាប់ក្អែលនៅអាងងូតទឹក បង្គន់ កន្លែងលុបមុខ（សូមសម្អាតអោយបានស្អាត）

・ នៅពេលដែល「លោកអ្នក」ធ្វើអោយបាត់ឬខូចសោផ្ទះ

・ បើសិនជា「លោកអ្នក」បណ្តោយអោយដុះស្មៅនៅក្នុងសួន

（សូមបោសសម្អាតនឹងដកស្មៅនៅក្នុងសួន）

**E　ការអោយតំណឹងមុនពេលរើចេញ（ប្រាប់ទៅកុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះថានឹងត្រូវរើចេញ）**

○ នៅពេលដែល「លោកអ្នក」ចង់រើចេញពីបន្ទប់សូមអោយតំណឹងជាមុនទៅ「កុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」

ថាចង់រើចេញនៅពេលណា

○ នៅក្នុងកិច្ចកុងត្រាជួលផ្ទះមានចុះលក្ខខណ្ឌកំណត់អោយប្រាប់「ត្រឹមរយះពេលប៉ុន្មានខែ」មុននឹងរើចេញ។

នៅពេលដែលប្រាប់ទៅ「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」នូវថ្ងៃរើចេញសូមកុំភ្លេចណាត់ថ្ងៃដែលពិនិត្យមើលបន្ទប់ថាមានខូចខាតអ្វីខ្លះ។

○ បើសិនជាលោកអ្នកផ្តល់តំណឹងយឺតពេលខុសពីលក្ខខណ្ឌក្នុងកិច្ចកុងត្រានឹងតម្រូវអោយបង់ប្រាក់។（សូមមេត្តាប្រុងប្រយត្ន័）

**F　ការរើចេញពីបន្ទប់(រើអីវ៉ាន់ចេញពីបន្ទប់ដែលជួល)**

○ ពេលរើចេញពីបន្ទប់ដែលជួលសូមរក្សាភាពថ្លៃថ្នូ

・ អីវ៉ាន់ដែល「លោកអ្នក」យកមកដាក់សូមយកចេញអោយអស់

・ កុំបន្សល់ទុកសំរាមឬគ្រឿងសង្ហារឹមដែល「លោកអ្នក」មិនត្រូវការ

・ សូមសម្អាតបន្ទប់អោយបានស្អាត

G　សូមលោកអ្នកជួសជុលធ្វើអោយមានភាពដូចដើមវិញ（បាននយ័ថាដូចពេលដែលមុននឹងចូលមករស់នៅ)

○　សូមយកសំរាមឬគ្រឿងសង្ហារឹមរបស់「លោកអ្នក」ចេញពីបន្ទប់ហើយសម្អាតបន្ទប់អោយបានស្អាត។

បើមានការខូចខាតនៅក្នុងបន្ទប់សូមជួសជុល។

○បើសិនជា「លោកអ្នក」បន្សល់ទុកនៅអីវ៉ាន់(គ្រឿងសង្ហារឹមឬសំរាម)「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」

នឹងត្រូវបង់ប្រាក់សំរាប់យកចោល។

○បើសិនជា「លោកអ្នក」មិនបានសម្អាតបន្ទប់នៅពេលរើចេញ「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」

នឹងជួលក្រុមហ៊ុនជំនាញអោយមកសម្អាត។

○នៅពេលដែល「លោកអ្នក」មិនអាចជួសជុលក្នុងការខូចខាតបន្ទប់ដោយផ្ទាល់ចំបាច់ត្រូវតែជួលក្រុមហ៊ុនជំនាញអោយមកជួសជុល។

○ក្រោយពីក្រុមហ៊ុនសម្អាតជួសជុលនឹងយកអីវ៉ាន់ចោល「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」នឹងទូទាត់ជាមួយប្រាក់កក់ដែល

「លោកអ្នក」បានដម្កល់ទុក។ក្នុងករណីខ្វះប្រាក់លោកអ្នកត្រូវបង់បន្ថែម។

H　ការពិនិត្យមើលបន្ទប់នៅពេលរើចេញ

(រវាងលោកអ្នកនឹងក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះត្រូវពិនិត្យមើលជាមួយគ្នាថាតើមានកន្លែងណាប្រឡាក់ឬខូចខាតឬក៏អត់។)

○　　នៅពេលដែល「លោកអ្នក」សម្អាតបន្ទប់ធ្វើអោយមានភាពដូចដើមវិញហើយត្រូវពិនិត្យមើលជាមួយ「ក្រុមហ៊ុនអចលនទ្រព្យ

ឬម្ចាស់ផ្ទះ」ថាតើមានកន្លែងណាប្រឡាក់ឬខូចខាតឬក៏អត់។

○　បើសិនជាលោកអ្នកប្រើប្រាស់បន្ទប់តាមធម្មតាហើយមានការប្រឡាក់នោះ「ម្ចាស់ផ្ទះ」នឹងចេញថ្លៃជួសជុល។

ក្រៅពីនេះលោកអ្នកត្រូវបង់ថ្លៃជួសជុលផ្ទាល់ខ្លួន។

○បើក្នុងកិច្ចកុងត្រាមានចុះ「លក្ខខណ្ឌពិសេស」បុគ្គលនៅក្នុងលក្ខខណ្ឌនោះហើយដែលត្រូវបង់ថ្លៃខូចខាត។（មានករណីដែល

「លោកអ្នក」ត្រូវបង់ប្រាក់ដោយខ្លួនឯងផងដែរ)

○ដើម្បីអោយបានដឹងថាអ្នកណាត្រូវបង់ប្រាក់ចំនួនប៉ុន្មាននោះ「លោកអ្នក」ត្រូវពិនិត្យមើលជាមួយ

「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」

○ក្នុងករណីមិនអាចពិនិត្យមើលជាមួយគ្នាបានសូម「លោកអ្នក」

ពិនិត្យបន្ទប់ដោយខ្លួនឯងហើយកត់ត្រាទុកតាមការមើលឃើញ។យកល្អសូមថតរូបទុកដោយមានចុះថ្ងៃខែ។

I　ក្រុមហ៊ុនជំនាញនឹងជួសជុលអោយមានភាពដូចដើមវិញ(ដូចពេលដែលមុននឹងចូលមករស់នៅ)

○　កន្លែងណាដែល「លោកអ្នក」មិនបានជួសជុលឬមិនអាចជួសជុល ក្រុមហ៊ុនជំនាញនឹងជួសជុលធ្វើអោយមានភាពដូចដើមវិញ ។

J　ការទូទាត់ប្រាក់ក្នុងការជួសជុលអោយធ្វើអោយមានភាពដូចដើម

○ត្រូវចំណាយប្រាក់ដើម្បីជួសជុលអោយមានភាពដូចដើមឬត្រូវចំណាយប្រាក់ដើម្បីចោលសម្ភារៈដែល「លោកអ្នក」បានបន្សល់ទុក។

○「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」ត្រូវទូទាត់ប្រាក់អោយទៅក្រុមហ៊ុនសម្អាតផ្ទះ,ក្រុមហ៊ុនជួសជុលផ្ទះ,នឹងក្រុមហ៊ុនរើសំរាម។

K　ការទូទាត់ប្រាក់ក្នុងការជួសជុលអោយមានភាពដូចដើម

ការទូទាត់ជាមួយប្រាក់កក់(ក្រុមហ៊ុនជំនាញនឹងជួសជុលធ្វើអោយមានភាពដូចដើមវិញ។ហើយប្រាក់សេសសល់នឹងត្រូវសងជូនក្នុងករណីខ្វះនឹងតម្រូវអោយលោកអ្នកបង់ប្រាក់បន្ថែម។

○តាមធម្មតាប្រាក់កក់នឹងត្រូវបានសងវិញនៅពេលដែល「លោកអ្នក」

រើចេញ។ក៍ប៉ុន្តែដោយត្រូវយកទៅចំណាយទៅលើការជួសជុលអោយមានភាពដូចដើមវិញឬចំណាយទៅលើការយកចោលនូវសំរាមឬសម្ភារៈដែលលោកអ្នកបានបន្សល់ទុក។

○ក្រោយពីទូទាត់ទៅលើការចំណាយធ្វើអោយមានភាពដូចដើមរួចប្រាក់សេសសល់នឹងត្រូវបានសងជូនទៅ「លោកអ្នក」វិញ។

○ករណីខ្វះប្រាក់ចំណាយទៅលើការជួសជុលអោយមានភាពដូចដើមនឹងតម្រូវអោយ「លោកអ្នក」បង់បន្ថែមទៅកាន់

「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」

## សូមចចារគ្នាបើមានការមិនសុខចិត្តក្នុងប្រការណាមួយ

・នៅពេលដែល「លោកអ្នក」រើចេញរួចរាល់ហើយក្រុមហ៊ុនសម្អាតផ្ទះ,ក្រុមហ៊ុនជួសជុលផ្ទះនឹងទូទាត់ប្រាក់។

・សូមសុំលិខិតរាយអំពីទឹកប្រាក់ដែលត្រូវចំណាយពី「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」ដើម្បីអោយដឹងថាតើ
ត្រូវចំណាយទៅលើការប្រឡាក់ឬបែកបាក់ខូចខាតអ្វីខ្លះ

・ត្រូវពិនិត្យមើលលិខិតរាយទឹកប្រាក់អោយបានច្បាស់ថាតើខ្លឹមសារនៃ「C ការពិនិត្យបន្ទប់មុនពេលចូលរស់នៅ」នឹង
「H ការពិនិត្យបន្ទប់នៅពេលរើចេញ」នោះសមស្របគ្នាដែរឬទេ។

・បើមានការមិនសុខចិត្តក្នុងលិខិតរាយទឹកប្រាក់សូមទំនាក់ទំនងទៅកាន់「ក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះ」
ដើម្បីទទួលការពន្យល់អោយបានក្បោះក្បាយ។

・សិនជាលោកអ្នកប្រើប្រាស់បន្ទប់តាមធម្មតា(ដូចជារស់នៅជាយូរឆ្នាំតាមធម្មតាហើយត្រូវប្រឡាក់ឬរហែក)ម្ចាស់ផ្ទះនឹងចេញថ្លៃជួសជុលដើម្បីអោយមានភាពដូចដើម។ តែបើលោកអ្នកប្រើប្រាស់បន្ទប់មិនធម្មតាឬមិនថែទាំ「លោកអ្នក」ត្រូវបង់លុយថ្លៃជួសជុលដោយផ្ទាល់ខ្លួន។